# ចាប់បានអណ្តើក៥២ក្បាលដឹកតាមឡានពាក់ស្លាកលេខខ.មក្លែងក្លាយ



សមត្ថកិច្ចចម្រុះចាប់សត្វអណ្តើក និងជនល្មើស២នាក់ (រូបថត:ព.ស)

**ពោធិ៍សាត់:** អណ្តើក៥២ក្បាល ដែលមានទម្ងន់សរុបដល់ទៅ ៣៥៨គីឡូក្រាម ត្រូវបានកម្លាំងចម្រុះខេត្តពោធិ៍សាត់ស្ទាក់ចាប់បានកាលពីវេលាម៉ោង១០និង៣០នាទីយប់ថ្ងៃទី១៤សីហានេះ ក្នុងខណៈរថយន្តល្មើសដឹកអណ្តើកពាក់ស្លាកលេខ(ខ.ម)ក្លែងក្លាយធ្វើដំណើរឆ្ពោះទៅកាន់ក្រុងភ្នំពេញ ។

ប្រតិបត្តិការបង្ក្រាបដោយចាប់បានអណ្តើកធំៗដែលខ្លះមានទម្ងន់ជិត១៥គីឡូក្រាមក្នុងមួយក្បាលនោះ បានធ្វើឡើងដោយមានការចូលរួមសហការគ្នារវាងប៉េអឹមស្នាក់ការ-សន្តិសុខ៥០២ ដឹកនាំដោយលោកញឹប-ដាំ ប៉ូលិសសេដ្ឋកិច្ចក្រសួងដឹកនាំដោយលោកឈឿន វណ្ណារ៉ា ផ្នែករដ្ឋបាលព្រៃឈើក្រគរ ដឹកនាំដោយលោកហ្គួត-ប៊ុនណុល និងប៉ូលិសសេដ្ឋកិច្ចលោកស្បៀន វីរៈ ។

លោកញឹម ដាំ ប្រធានស្នាក់ការសន្តិសុខ៥០២បានឱ្យដឹងថា បន្ទាប់ពីភ្នាក់ងាររាយការណ៍ពីខេត្តបន្ទាយមានជ័យមកថា មានរថយន្តមួយគ្រឿងពណ៌ត្រៃអ៊ីពាក់ស្លាកលេខ(ខ.ម)ដឹកសត្វអណ្តើកបទល្មើសច្បាប់បានធ្វើដំណើរឆ្ពោះចូលមកក្នុងទឹកដីខេត្តពោធិ៍សាត់នោះ រូបលោកក៏បានទំនាក់ទំនងកម្លាំងសមត្ថកិច្ចចម្រុះជួយស្ទាក់គ្រប់ច្រកតាមផ្លូវជាតិលេខ៥ ។ លោកបន្តថា នៅវេលាដូចខាងលើមុខសញ្ញារថយន្តល្មើសបានបើកយ៉ាងលឿនហើយក៏ត្រូវសមត្ថ-

តទៅទំព័រ ក៧

តមកពីទំព័រ ក៨

## ចាប់បានអណ្តើក...

កិច្ចចម្រុះស្ទាក់ចាប់បាននៅចំណុចភូមិសានស ឃុំអន្សារចំបក់ ស្រុកក្រគរ ។ បន្ទាប់មកក៏បានបញ្ជូនទាំងមនុស្សនិងវត្ថុល្មើសទាំងអស់មកទីបញ្ជាការប៉េអឹមខេត្តទាំងយប់ ។

មន្ត្រីប៉េអឹមខេត្តឱ្យដឹងថា ក្នុងកិច្ចសហការបង្ក្រាបនេះ កម្លាំងចម្រុះបានធ្វើការឃាត់ខ្លួនបុរសពីរនាក់ទី១-ឈ្មោះគី សក្តដា ភេទប្រុស អាយុ៣១ឆ្នាំ មានឋានៈជាអនុសេនីយ៍ទោយោធាព្រំដែនគោកលេខ៥០៣ និងទី២ឈ្មោះថន វណ្ណៈ ភេទប្រុស អាយុ២៨ឆ្នាំ ជាពលទោបម្រើការនៅអង្គភាពជាមួយគ្នា ។ ឃាត់ទុករថយន្តមួយគ្រឿងម៉ាកសាំយ៉ុង (SAMYON) ពណ៌ត្រៃអ៊ីពាក់ស្លាកលេខ(ខ.ម២.០១៥៥)ក្លែងក្លាយ រួមនឹងសត្វអណ្តើក៥ប្រាវចំនួន៥២ក្បាល ស្មើនឹង៣៥៨គីឡូក្រាម ។ នៅរសៀលថ្ងៃទី១៥សីហានេះ ខាងកម្លាំងចម្រុះក៏បានប្រគល់អណ្តើកទៅឱ្យអង្គការការពារសត្វព្រៃ (Wild Aid) ដើម្បីយកទៅលែងក្នុងទីសុវត្ថិភាពណាមួយដូចជាសួនសត្វភ្នំតាម៉ៅ ឬបឹងទន្លេសាបជាដើម។

ចំណែកជនល្មើសត្រូវបានផ្នែករដ្ឋបាលព្រៃឈើរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ។ ឯប្រាក់ផាកពិន័យជនល្មើស២៣.៥០០បាត អាយកូមមួយគ្រឿង ទូរស័ព្ទដៃមួយគ្រឿង ត្រូវបានជំនាញមេព្រៃធ្វើកំណត់ហេតុសុំដកទុកបណ្តោះអាសន្ន ។

សត្វអណ្តើកដែលមានទំហំធំៗដែលខ្លះមានទម្ងន់ដល់ជិត១៥គីឡូក្រាមក្នុងមួយក្បាលនោះត្រូវបានគេគិតថា ជាសត្វដែលពួកឈ្មួញសម្រាំងទុកដោយកម្រ ដែលអណ្តើកទាំងនោះមានអណ្តើកសកល អណ្តើកសោម ។

មន្ត្រីអង្គការ Wild Aid និយាយថា សត្វអណ្តើកទាំងនោះអាចត្រូវបានជនល្មើសលួចចាប់ពីដែនជម្រកសត្វព្រៃណាមួយនៅក្នុងប្រទេសថៃ ។ សត្វទាំងនោះត្រូវគេធ្វើចរាចរជំនួញទៅកាន់ប្រទេសវៀតណាម រួចបន្តទៅកាន់ប្រទេសចិនទៀត ដែលនៅទីនោះវាមានតម្លៃខ្ពស់ ។ មន្ត្រីដដែលឱ្យដឹងថា កន្លងមកអង្គការរបស់លោកក៏ធ្លាប់ចាប់បានសត្វអណ្តើកទាំងនោះបានជាច្រើនក្បាលផងដែរ ហើយបានយកទៅលែងកន្លែងសុវត្ថិភាពបឹងទន្លេសាបក្នុងទឹកដីខេត្ត-កំពង់ឆ្នាំង ។

ព.ស